ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## កិច្ចប្រជុំរួមប្រចាំខែមករា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន



ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩

នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង០៩:០០នាទីព្រឹក នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំប្រចាំខែមករា ឆ្នាំ២០១៩ ដែលដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមានៈ អគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិកទាំងអស់ចំនួន៥៩នាក់ (បញ្ជីវត្តមានភ្ជាប់ជាមួយ)។

**អវត្តមានៈ**

| | | |
|---|---|---|
| ១-លោកវេជ្ជ. | លី ចាន់ក៉ាវុធ | (ប្រជុំនៅខាងក្រៅ) |
| ២-លោក | ឈុន វ៉ាន់ធី | (ច្បាប់) |
| ៣-លោកស្រី | ឈី ប្រាថ្នា | (ឥតច្បាប់) ? |
| ៤-លោកទន្តបណ្ឌិត | ស្រេង ហេង | (ច្បាប់) |
| ៥-លោក | កុយ តារាវន្ត | (ច្បាប់) |
| ៦-លោកស្រី | អ៊ឹម ស្រីណាន | (ច្បាប់) |
| ៧-លោកស្រី | ព្រាប សុជាតា | (ច្បាប់) |

**គោលបំណងនៃកិច្ចប្រជុំនេះមាន ៖**

១-សេចក្តីរាយការណ៍របស់នាយកដ្ឋានបច្ចេកទេស
២-ការងាររដ្ឋបាល
៣-ផ្សេងៗ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបពីគោលបំណងនៃកិច្ចប្រជុំ ដោយផ្តោតជាសំខាន់ទៅលើការងាររដ្ឋបាល និងការផ្តល់ឱកាសដល់មន្ត្រីទាំងអស់លើកឡើងពីបញ្ហាទូទៅ និងពិភាក្សារកដំណោះស្រាយដើម្បីឱ្យស្ថាប័នរីកចម្រើន។

## ១-សេចក្តីរាយការណ៍របស់នាយកដ្ឋានបច្ចេកទេស

### ១.១. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

- បានធ្វើបច្ចុប្បន្នភាពសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ នឹងរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស
- មន្ត្រីចំនួន ៥រូបនៅក្នុងនាយកដ្ឋាន បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់ តាមរយៈដៃគូសហគមន៍( MCPI ) នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ នឹងរៀបចំពិធីផ្សព្វផ្សាយពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងឱកាសបុណ្យទិវានៃក្តីស្រឡាញ់ នៅខាងមុខអគារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ១.២. នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

- ចងក្រងរបាយការណ៍សកម្មភាព និងលទ្ធផលរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមករា ឆ្នាំ២០១៩។
- បានបញ្ចប់សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ជាពហុវិស័យនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០១៨។
- បានចូលរួមកិច្ចប្រជុំបច្ចេកទេស ស្តីពីទំនាក់ទំនងរវាងផែនការអភិវឌ្ឍន៍ជាតិ(NSDP)ដែល បានគាំទ្រថវិការៀបចំដោយក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានរៀបចំកែសម្រួលភារកិច្ចទទួលខុសត្រូវរបស់មន្ត្រីក្នុងនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ ដាក់ជូនអគ្គលេខាធិការពិនិត្យ និងផ្តល់ការយល់ព្រម។
- បានរៀបចំកិច្ចប្រជុំនាយកដ្ឋាន ដើម្បីពង្រឹងរបៀបរបបការងារ និងបែងចែកភារកិច្ចទទួល ខុសត្រូវរបស់មន្ត្រីនៅក្នុងនាយកដ្ឋាន។
- រៀបចំផែនការរបស់នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ និងចងក្រង ផែនការរបស់អគ្គលេខាធិការដ្ឋានសម្រាប់ឆ្នាំ២០១៩។
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីសៀវភៅបណ្តុះបណ្តាលបរិយាកាសគាំទ្រ ច្បាប់ និងគោល នយោបាយក្នុងការគាំទ្រការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍។
- រៀបចំសម្របសម្រួលកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិ ស្តីពីការពិនិត្យឡើងវិញនូវផែនការយុទ្ធ សាស្ត្រជាតិលើកទី៤ និងការរៀបចំផែនការយុទ្ធសាស្ត្រជាតិលើកទី៥។
- បានចូលរួមកិច្ចប្រជុំរៀបចំសេចក្តីព្រៀងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៩។
- បានចូលរួមប្រជុំអន្តរក្រសួង ស្តីពីការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្លើយតបគោលដៅ អភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ផ្ញើជូនអង្គការសហប្រជាជាតិ។
- នឹងបញ្ចប់របាយការណ៍វឌ្ឍនភាព នៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆ្នាំ ២០១៨។
- នឹងបញ្ចប់ផែនការសកម្មភាពរបស់នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ សម្រាប់ឆ្នាំ២០១៩ ដាក់ជូនឯកឧត្តមអគ្គលេខាធិការពិនិត្យ និងផ្តល់ការយល់ព្រម។
- នឹងត្រៀមរៀបចំសិក្ខាសាលា ស្តីពីធ្វើផែនការប្រចាំឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធនឹង ជំងឺអេដស៍ខែមីនា ឆ្នាំ២០១៩។
- នឹងបញ្ចប់សេចក្តីព្រាងឯកសារ ដើម្បីពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិឆ្លើយតប មេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ សម្រាប់ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការពិនិត្យឡើងវិញ នូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការរៀបចំផែនការយុទ្ធសាស្ត្រ ជាតិលើកទី៥។

## ១.៣. នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ

- បានប្រជុំក្រុមការងារថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីកំណត់សកម្មភាព រយៈពេល៥ឆ្នាំបន្ទាប់ (២០១៩-២០២៣) បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី ៥ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- បានបញ្ចប់ការធ្វើផែនការសកម្មភាពឆ្នាំ២០១៩ របស់នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ។
- នឹងរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីយន្តការបរិយាកាសគាំទ្រដល់ក្រុមប្រជាជនប្រឈមមុខខ្ពស់ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានរយៈពេល២ថ្ងៃ នៅខេត្តសៀមរាប និងព្រះសីហនុ។

២. ការងាររដ្ឋបាល

- បានទាក់ទង និងធ្វើលិខិតទៅអគ្គនាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំមន្ត្រីមកធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អំពីការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ។ ការបណ្តុះបណ្តាលនេះ គ្រោងនឹងធ្វើនៅថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៩ នៅខេត្តកំពត។
- បានរៀបចំលិខិតចាត់តាំងមន្ត្រីចំនួន៣០នាក់ ទៅចូលរួមក្នុងពិធីបុណ្យខួបលើកទី៤០ នៃទិវាជ័យជម្នះ៧មករា ឆ្នាំ២០១៩ នៅពហុកីឡដ្ឋានជាតិអូឡាំពិក។
- បានជូនដំណឹងដល់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៅក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យប្រើប្រាស់គណនីសំបុត្រអេឡិចត្រូនិចផ្លូវការ name@naaa.gov.kh នៅក្នុងការទំនាក់ទំនងការងារផ្លូវការ។
- បានរៀបចំឯកសារជូនឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីដឹកនាំប្រតិភូទៅចូលរួមសន្និសីទព្រះអង្គម្ចាស់ម៉ាហ៊ីដុល(PMAC) ដែលប្រារព្ធឡើងពីថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩ នៅទីក្រុងបាងកក ប្រទេសថៃ តាមលិខិតលេខ១៥០៥ សជណ.វអ ចុះ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨។
- បានការកែសម្រួលការបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់អគ្គលេខាធិការរង នៅក្នុងអគ្គលេខាធិការដ្ឋាន។
- បានជូនដំណឹងដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្នុងអគ្គលេខាធិការដ្ឋាន ពីកម្មវិធីប្រជុំប្រចាំខែនីមួយៗក្នុងឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានបញ្ជូនលិខិតណែនាំទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ស្តីពីការចងបដាបញ្ជ្រាបសារអប់រំបង្ការមេរោគអេដស៍ និងជំងឺអេដស៍នៅគ្រប់កម្មវិធីប្រកួតកីឡារបស់សហព័ន្ធកីឡាបាល់ទាត់កម្ពុជា នៅតាមបណ្តារាជធានី ខេត្ត។
- បានរៀបចំលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រីប្រចាំខែមករា ឆ្នាំ២០១៩ ចំនួន៣៣។
- បានចែកលិខិតអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីនៅក្នុងអគ្គលេខាធិការដ្ឋាន ដើម្បីចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមករា ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រី នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩។
- បានប្រជុំផ្ទៃក្នុងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងកែសម្រួលផែនការសកម្មភាពឆ្នាំ២០១៩ របស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។
- បានកែសម្រួលផែនការបេសកកម្មរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០១៩។

- បានរៀបចំសំណុំឯកសារទៅក្រសួងសុខាភិបាល ដើម្បីស្នើសុំមន្ត្រីជាប់កិច្ចសន្យាចំនួន ២៤នាក់ ឱ្យចូលបម្រើការងារនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងឆ្នាំ២០១៩។
- បានដំឡើងម៉ាស៊ីនផ្តិតស្នាមក្រយៅដៃ ដើម្បីស្រង់វត្តមានមន្ត្រីរាជការចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩។
- បានប្រជុំផ្ទៃក្នុងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងកែសម្រួលបំណែងចែកតួនាទី និងភារកិច្ចការងាររបស់មន្ត្រីនៅក្នុងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩។
- រៀបចំសំណុំឯកសារទៅក្រសួងសុខាភិបាល ដើម្បីស្នើសុំតែងតាំងស៊ប់បញ្ចូលក្នុងក្របខ័ណ្ឌជូនមន្ត្រីកម្មសិក្សាចំនួន១០រូប។
- បានប្រជុំថ្នាក់ដឹកនាំ និងមន្ត្រីក្នុងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងកែសម្រួលបំណែងចែកតួនាទី និងភារកិច្ច ក្រោមអធិបតីភាពឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩។
- បានរៀបចំកិច្ចប្រជុំគណៈកម្មការវាយតម្លៃមន្ត្រីកម្មសិក្សាចំនួន១០រូប ដើម្បីស្នើសុំតែងតាំងស៊ប់បញ្ចូលក្នុងក្របខ័ណ្ឌនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩។
- ការិយាល័យបុគ្គលិក និងបៀវត្សពលកម្ម បានទៅរកមើល និងទទួលប័ណ្ណបេបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការចំនួន២៦ ពីក្រសួងសុខាភិបាល។
- បានរៀបចំឯកសារបិទបញ្ជីចំណាយថវិកាឆ្នាំ២០១៨ បានចប់ជាស្ថាពរ។
- ដាក់លិខិតទៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីស្នើសុំដកថវិការដ្ឋទេយ្យជុំទី១។
- បានរៀបចំផែនការចំណាយបេសកកម្មរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ២០១៩។
- បានរៀបចំបែងចែកសម្ភារការិយាល័យប្រចាំត្រីមាសទី១ ជូនថ្នាក់ដឹកនាំ និងនាយកដ្ឋាន។
- បានបញ្ចប់ការធ្វើសវនកម្ម ពីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលចុះមកធ្វើសវនកម្មនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចាប់ពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៨ ដោយជួបពិភាក្សាអំពីរបាយការណ៍នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩។
- បានទទួលក្រុមការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានមកពិនិត្យទីតាំង និងស្ថានភាពដើម្បីរៀបចំដំឡើងប្រព័ន្ធកុំព្យូទ័រចំនួន៤គ្រឿង Printer១ឬ២គ្រឿង និងServer នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨។
- កំពុងរៀបចំប្រកាស ស្តីពីការបង្កើតជុំរដ្ឋទេយ្យឆ្នាំ២០១៩ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយធ្វើការជាមួយរតនាគារជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ឯកឧត្តមប្រធានអង្គប្រជុំបានណែនាំដូចខាងក្រោម៖**

១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវរៀបចំលិខិតឧទ្ទេសនាមក្រុមការងារ ដើម្បីចុះចងបដាបញ្ជ្រាបសារអប់រំបង្ការមេរោគអេដស៍ និងជំងឺអេដស៍នៅគ្រប់កម្មវិធីប្រកួតកីឡារបស់សហព័ន្ធកីឡាបាល់ទាត់កម្ពុជានៅតាមបណ្តារាជធានី ខេត្ត។

២. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវធ្វើផែនការថវិកាឆ្នាំ២០១៩ ដែលត្រូវផ្តល់ជូនទៅឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង និងរាជធានី ខេត្ត សម្រាប់រៀបចំកិច្ចប្រជុំឱ្យបានច្បាស់លាស់។

៣. នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ត្រូវរៀបចំលិខិតចាត់តាំងគណៈកម្មការវាយតម្លៃបោយការណ៍គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង និងរាជធានី ខេត្ត។

៤. ស្នើមន្ត្រីទាំងអស់ ត្រូវគោរពវិន័យ បទបញ្ជាផ្ទៃក្នុង និងមានអាកប្បកិរិយាសមរម្យនៅក្នុងម៉ោងធ្វើការងារ។

៥. នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ ត្រូវភ្ជាប់ឱ្យបានពីទិន្នន័យក្រុមប្រឈម អ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ កុមារកំព្រាដែលផ្ទុកមេរោគអេដស៍...។ល។ ទូទាំង២៥រាជធានី ខេត្ត។

៦. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន និងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវពិនិត្យមើលលទ្ធភាព និងជជែកពិភាក្សាគ្នា ដើម្បីរៀបចំពិធីផ្សព្វផ្សាយពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងឱកាសបុណ្យទិវានៃក្តីស្រឡាញ់ ដែលនឹងគ្រោងធ្វើនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៩ នៅខាងមុខអគារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៧. ប្រធាននាយកដ្ឋាននីមួយៗ ត្រូវពិនិត្យ និងពង្រឹងឡើងវិញនូវវត្តមានរបស់មន្ត្រីក្រោមឱវាទ។ ក្នុងករណីអវត្តមាន ត្រូវមានឯកសារ និងលិខិតសុំច្បាប់លាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់។ ការិយាល័យបុគ្គលិក និងបៀវត្សពលកម្ម នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់ពីវត្តមានរបស់មន្ត្រីរវាងស្នាមផ្តិតក្រយៅដៃជាមួយម៉ាស៊ីន និងលិខិតស្នាម ដែលពាក់ព័ន្ធ។

៨. ប្រធាននាយកដ្ឋាននីមួយៗ ត្រូវចាត់តាំងមន្ត្រីម្នាក់នៅក្នុងនាយកដ្ឋាន ឱ្យទទួលបន្ទុកព័ត៌មាន ទទួលខុសត្រូវក្នុងការតាមដានរាល់ឯកសាររបស់នាយកដ្ឋានដែលត្រូវបញ្ចូលទៅក្នុងគេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាទីបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានផ្តល់ការលើកទឹកចិត្តដល់មន្ត្រីទាំងអស់ ឱ្យខិតខំបំពេញការងារបន្តទៅទៀត រក្សាសាមគ្គីភាពផ្ទៃក្នុង និងទទួលខុសត្រូវខ្ពស់លើការងាររបស់ខ្លួន។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១និង០០នាទី នាថ្ងៃខែឆ្នាំដដែលប្រកបដោយភាពស្និទ្ធស្នាល និងរីករាយ៕

**អ្នកធ្វើរបាយការណ៍**

**ហ៊ុន ស**

បានឃើញ និងឯកភាព
**ប្រធានអង្គប្រជុំ**

បានពិនិត្យត្រឹមត្រូវ
**ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**